# របាយការណ៍វឌ្ឍនភាពត្រីមាសទី៣ ស្តីពី
# លទ្ធផល នៃការអនុវត្តន៍គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ច

ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០១៧

**១-ក្រុមហ៊ុនឈ្មោះ** ៖ ហ្រ្គេនឌីស ធីមប៊ើរ អិលធីឌី

**២-ទីតាំងនិងទំហំផ្ទៃដី** ៖ ស្រុកភ្នំស្រួច និងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានទំហំផ្ទៃដីសរុប ៧.៨៩៦,១១ ហិកតា

**៣-ប្រភេទដំណាំ** ៖ ដើមឈើម៉ៃសាក់

**4-ផែនការមេ** ៖ ក្រសួង ☑ ឬ ខេត្ត ☐ ឯកភាពតាមលិខិតលេខ ៣២៥៩/៣៣៦ កសក.រផ.ផក ចុះថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**៥-ការចុះបញ្ជីដីរដ្ឋ** ៖ បានទទួលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំនួន ១៧ ក្បាលដី

- បានអនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ (ជូនភ្ជាប់ប្លង់ក្បាលដី ១៧ ក្បាលដី)
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ
- មិនបានអនុវត្ត ☐ មូលហេតុ

**៦-អនុបយោគ** ៖ វិញ្ញាបនប័ត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច ចំនួន ១៧

- បានអនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ (វិញ្ញាបនប័ត្រ និងអនុក្រឹត្យស្តីពីការរៀបចំអនុបយោគ)
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ
- មិនបានអនុវត្ត ☐ មូលហេតុ

**៧-របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖**

- បានអនុវត្តរួចរាល់ ☑ ស្នើផ្តល់ឯកសារ (លិខិតលេខ ១៧២ ស.ជ.ណ ប.ស្ព ចុះថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០១៤ របស់ក្រសួងបរិស្ថាន ឯកភាពលើរបាយការណ៍វាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គមបឋម)
- កំពុងអនុវត្ត ☐ ដល់ណាស្នើបញ្ជាក់ និងផ្តល់ឯកសារ
- មិនបានអនុវត្ត ☐ មូលហេតុ

**៨-លិខិតអនុញ្ញាតឲ្យឈូសឆាយ៖** មាន ☐ គ្មាន ☑ អនុញ្ញាតដោយក្រសួង ឬខេត្ត លិខិតលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់ (ក្រុមហ៊ុនមានគម្រោងឈូសឆាយផ្ទៃដីទំហំ ១២១២ ហិកតា ស្ថិតក្នុងអនុតំបន់លេខ ៧ ៨ ៩ និង១០ នៅក្នុងភូមិសាស្ត្រឃុំស្មើសាមគ្គី ស្រុកឱរ៉ាល់ ហើយក្រុមហ៊ុនបានដាក់សំណើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៦ រួចរាល់ហើយដែរ ប៉ុន្តែមិនទាន់មានការឆ្លើយតបវិញ។ រហូតមកដល់ពេលនេះក្រុមហ៊ុនបានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ ដើម្បីពិនិត្យជាក់ស្តែងពីវឌ្ឍនភាពគម្រោង និងស្ថានភាពព្រៃឈើនៅទីតាំងដែលបានស្នើសុំឈូសឆាយ ដោយអនុឡោមតាមលិខិតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានរាយការណ៍ជូនក្រសួងវិញតាមរបាយការណ៍លេខ ១២៣ កសរន.កសព ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១៧។ ដោយឡែក នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ មន្ត្រីបច្ចេកទេសរដ្ឋបាលព្រៃឈើ នៃរដ្ឋបាលព្រៃឈើថ្នាក់កណ្តាលបានចុះធ្វើការវាយតម្លៃធនធានព្រៃឈើដោយរហ័សបន្ថែមទៀត ដើម្បីមានមូលដ្ឋានបច្ចេកទេសសម្រាប់រាយការណ៍ជូនក្រសួងពីស្ថានភាពធនធានព្រៃនៅតំបន់ស្នើសុំឈូសឆាយរបស់ក្រុមហ៊ុនហ្រ្គេនឌីស ធីមប៊ើរ អិលធីឌី ផងដែរ។ មកដល់ពេលនេះ រដ្ឋបាលព្រៃឈើបានរាយការណ៍រួចរាល់តាមរយៈរបាយការលេខ ២២១៩ រព.នពស និងបានបញ្ជូនដល់ក្រសួង

កសិកម្មលេខ ២៦៤៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧។ ដូចនេះ ជំហានបន្ទាប់ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពិនិត្យ និងសម្រេចលើសំណើរបស់ក្រុមហ៊ុន។

**៩-ទីតាំង និងទំហំផ្ទៃដីដែលអនុញ្ញាតឲ្យឈូសឆាយដាំដុះ៖**

- អនុតំបន់ទី គ្មាន ទំហំ គ្មាន ហិកតា (ស្នើភ្ជាប់ឯកសារ)

**១០-លទ្ធផលអនុវត្តបាន៖** (ប្រសិនបើមានការអនុវត្តច្រើនអនុតំបន់ ស្នើរាយការណ៍តាមអនុតំបន់នីមួយៗ)

**១០.១-ការឈូសឆាយ-ដាំដុះ**

- ឈូសឆាយបាន/ឈូសឆាយឡើងវិញ ១៧០,២៨ ហិកតា ក្នុងអនុតំបន់ទី ៣ និង៦ (រៀបចំដីដាំឡើងវិញ)
- ដាំដុះបាន/ដាំឡើងវិញ ៣៦,១៦ ហិកតា ប្រភេទដំណាំ ម៉ៃសាក់ អាកាស្យា និងប្រេងខ្យល់ ក្នុងអនុតំបន់ទី៣
- ផ្ទៃដីនៅសល់មិនទាន់ដាំ ១៥២,២៨ ហិកតា ក្នុងអនុតំបន់ទី ៣ និង៦
- ផ្ទៃដីមិនអាចដាំដុះបាន ៨៥០,៨៥ ហិកតាក្នុងអនុតំបន់ទី ១ ដល់១០ ស្នើបញ្ជាក់ពីមូលហេតុដីមិនអាចដាំបាន៖ ជាតំបន់ការពារ មានដូចជា តំបន់ដីសើម ភ្នំ តំបន់ទំនាបអូរ ជាដើម។

*(ស្នើបញ្ជាក់ចំណុចនិយាមកាទីតាំងដាំដុះ និងភ្ជាប់មកជាមួយផែនទីតំបន់ដាំដុះ)*

**១០.២-ការងារសាងសង់៖**

- សាងសង់ផ្លូវក្នុងតំបន់ដីសម្បទានចំនួន ០៣ ខ្សែ ប្រវែង ០៨ គ.ម
- សាងសង់ផ្លូវក្រៅ តំបន់ដីសម្បទានចំនួន គ្មាន ខ្សែ ប្រវែង គ្មាន គ.ម
- ជួសជុលផ្លូវក្នុង តំបន់ដីសម្បទានចំនួន ០៨ ខ្សែ ប្រវែង ១៤,៥ គ.ម
- ជួសជុលផ្លូវក្រៅ តំបន់ដីសម្បទានចំនួន គ្មាន ខ្សែ ប្រវែង គ្មាន គ.ម
- ស្នាក់ការធំក្រុមហ៊ុនចំនួន គ្មាន ខ្នង ទំហំ ម² ស្នាក់ការរងក្រុមហ៊ុនចំនួន គ្មាន ខ្នង ទំហំ ម² ផ្ទះបុគ្គលិកស្នាក់នៅចំនួន គ្មាន ខ្នង ទំហំ ម² ផ្ទះកម្មករចំនួន គ្មាន ខ្នង ទំហំ ម²
- រោងជាងចំនួន គ្មាន ខ្នង ទំហំ ម² ឃ្លាំងចំនួន គ្មាន ខ្នង ទំហំ ម² ផ្ទះកម្មករចំនួន ខ្នង ទំហំ ម² ថ្នាលបណ្ដុះកូនឈើចំនួន គ្មាន ទំហំ ម²
- ការសាងសង់មណ្ឌលសុខភាពចំនួន គ្មាន ខ្នង ទំហំ ម²
- សាលារៀនចំនួន គ្មាន ខ្នង ទំហំ ម²
- សាលាបុណ្យចំនួន គ្មាន ខ្នង ទំហំ ម²
- ការសាងសង់សំណង់ផ្សេងៗ ........................................

**១០.៣-ការងារប្រមូលសំណល់ឈើពីការឈូសឆាយក្នុងតំបន់សម្បទាន៖**

- ឈើមូលសរុប គ្មាន ម³ បង់ថ្លៃសួយសារររួច គ្មាន ម³
- ឈើមូលសរុបនៅសល់មិនទាន់បង់ គ្មាន ម³ បញ្ជាក់មូលហេតុ៖ គ្មានការឈូសឆាយនោះទេ
- កូនឈើសរុប គ្មាន ដើម បង់ថ្លៃសួយសាររួច គ្មាន ដើម
- កូនឈើសរុបមិនទាន់បង់ គ្មាន ដើម បញ្ជាក់មូលហេតុ៖ គ្មានការឈូសឆាយនោះទេ
- អុសសរុប គ្មាន ស្ទែរ បង់ថ្លៃសួយសាររួច គ្មាន ស្ទែរ
- អុសសរុបមិនទាន់បង់ គ្មាន ស្ទែរ បញ្ជាក់មូលហេតុ៖ គ្មានការឈូសឆាយនោះទេ

**១០.៤-ការប្រើប្រាស់កម្លាំងពលកម្ម៖**

- បុគ្គលិកខ្មែរសរុប ៩៤ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ ៣៥២ ដុល្លាអាមេរិក

- បុគ្គលិកបរទេសសរុប ០១ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ ៨ ៥០០ ដុល្លារអាមេរិក
- កម្មករខ្មែរអចិន្ត្រៃយ៍សរុប គ្មាន នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ គ្មាន
- កម្មករបរទេសសរុប គ្មាន នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ គ្មាន
- កម្មករអណ្តែតសរុប ៣១៩ នាក់ ប្រាក់បៀវត្សប្រចាំខែក្នុងម្នាក់ ១១៧ ដុល្លារអាមេរិក

**១០.៥-ផ្ទៃដីប្រមូលផល៖**

- ទំហំផ្ទៃដីប្រមូលផលដំណាំចម្បង
  - ១. ប្រភេទដំណាំ គ្មាន ចំនួន គ្មាន ហិកតា អនុតំបន់ទី គ្មាន
  - ២.ប្រភេទដំណាំ គ្មាន ចំនួន គ្មាន ហិកតា អនុតំបន់ គ្មាន
- ទំហំផ្ទៃដីប្រមូលផលបន្ទាប់បន្សំ
  - ១.ដំណាំ គ្មាន ចំនួន គ្មាន ហិកតា អនុតំបន់ គ្មាន
  - ២.ដំណាំ គ្មាន ចំនួន គ្មាន ហិកតា អនុតំបន់ គ្មាន

**១០.៦-ការប្រើប្រាស់ផល-ផលិតផល៖**

- បរិមាណផល-ផលិតផលទទួលបានតាមប្រភេទដំណាំ៖
  - ដំណាំ គ្មាន ចំនួន គ្មាន តោន
  - ដំណាំ គ្មាន ចំនួន គ្មាន តោន
- បរិមាណនិងប្រភេទផល-ផលិតផលសរុបទទួលបាន៖
  - ដំណាំ គ្មាន ចំនួន គ្មាន តោន
  - ដំណាំ គ្មាន ចំនួន គ្មាន តោន
- បរិមាណនិងប្រភេទផល-ផលិតផលនាំចេញ៖
  - ដំណាំ គ្មាន ចំនួន គ្មាន តោន ទៅប្រទេស
  - ដំណាំ គ្មាន ចំនួន គ្មាន តោន ទៅប្រទេស
- បរិមាណនិងប្រភេទផល-ផលិតផលប្រើប្រាស់ក្នុងស្រុក៖
  - ដំណាំ គ្មាន ចំនួន គ្មាន តោន ទៅប្រទេស
  - ដំណាំ គ្មាន ចំនួន គ្មាន តោន ទៅប្រទេស

**១១.ការបង់ថ្លៃឈ្នួលសម្បទាន៖** មាន ☐ គ្មាន ☑ បើមាន៖ ក្រុមហ៊ុនយើងខ្ញុំបានទទួលរួចហើយនូវលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច សម្រាប់ឆ្នាំ២០១៦ក្នុងទំហំទឹកប្រាក់សរុបចំនួន ៤០ ២៧៤,១០ ដុល្លាអាមេរិក (សែសិបពាន់ពីររយចិតសិបបួន និងដប់សេន) ដែលទំហំផ្ទៃដីសរុបក្រោយចុះបញ្ជី និងរៀបចំអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ ទំហំសរុប៧ ៨៩៦,១១ ហិកតាត្រូវបានយកមកគណនាតម្លៃត្រូវបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច។

**១២.ទំនាស់ដីធ្លី និងការដោះស្រាយ៖** មាន ☑ គ្មាន ☐ បើមានស្នើអត្ថាធិប្បាយពី៖

- **ក-ទីតាំងទំនាស់ស្ថិតនៅអនុតំបន់ណា? ទំហំដីទំនាស់ប៉ុន្មានហិកតា? ចំណុចនិយាមកា?**

  **ករណីទី១៖** ក្បាលដីចុះបញ្ជីលេខ ខ.១១ និងខ.០៥ មានទំហំដីសរុប៣,៣៨ ហិកតា ជាវាលស្រែរបស់ប្រជាជន និងអូរធម្មជាតិ ដែលក្រុមហ៊ុនមិនអាចដាំដុះ ឬអភិវឌ្ឍបាន (ជូនភ្ជាប់ផែនទី)។

  **ករណីទី២៖** ប្រជាជន ៧ គ្រួសារមកពីភូមិព្រៃធំ ឃុំស្មើសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បានទាមទារធ្វើជាដីកម្មសិទ្ធិរស់នៅក្នុងអនុតំបន់ទី ៦ ទំហំផ្ទៃដីសរុប ៣,៥២ ហិកតា (ជូនភ្ជាប់ផែនទី)។

➢ **ខ-ថ្ងៃ/ខែ/ឆ្នាំកើតទំនាស់ មូលហេតុទំនាស់ និងឯកសារពាក់ព័ន្ធ**

**ករណីទី១៖** នៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៧ ក្រុមហ៊ុនបានចុះពិនិត្យជាក់ស្តែងត្រង់ក្បាលដីលេខ ខ.១១ និងខ.៥ ឃើញថា ក្បាលទីខ.១១ គឺជាវាលស្រែរបស់ប្រជាជនអាស្រ័យផល និងធ្វើស្រែជាក់ស្តែង ព្រោះថាមានទាំងដើមត្នោត និងភ្លឺស្រែ។ ចំណែកក្បាលដីលេខ.ខ០៥ វិញ គឺជាផ្ទៃអូរ ដែលក្រុមហ៊ុនមិនអាចដាំដុះបាន និងលើសពីនេះទៀត ក្រុមហ៊ុនត្រូវទទួលខុសត្រូវកិច្ចការពារបរិស្ថានទាំងជីវៈសាស្ត្រ រូបសាស្ត្រ និងសង្គមសាស្ត្រ។ ដូចនេះ រាល់ស្ទឹង បឹង អូរ ធម្មជាតិជាសម្បត្តិសារធារណៈរបស់រដ្ឋ (ច្បាប់ភូមិបាល ២០០១)។

**ករណីទី២៖** នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ក្រុមហ៊ុនបានទទួលលិខិតបញ្ជាក់សិទ្ធិកាន់កាប់ក្បាលដីចំនួន៧កន្លែង (ផែនទីខាងលើ) ពីប្រជាជនមកពី ៧ គ្រួសារ ដើម្បីសុំដំណោះស្រាយជាមួយក្រុមហ៊ុន។ លិខិតបញ្ជាក់នោះមាននចុះសហត្ថលេខា និងត្រា ដោយអាជ្ញាធរឃុំ និងភូមិ ទទួលស្គាល់សិទ្ធិកាន់កាប់ដីធ្លីទាំងនោះ (ជូនភ្ជាប់ផែនទី)។

➢ **គ-វិធានការដោះស្រាយ និងលទ្ធផលដោះស្រាយ**

**ករណីទី១៖** ក្រុមហ៊ុននឹងធ្វើការរៀបចំលិខិតជូនដំណឹងទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីស្ថានភាពជាក់ស្តែងនៅទីតាំងក្បាលដីទាំងនោះ ដើម្បីជូនជ្រាប និងមានវិធានការតាមការគួរ។ ក្រុមហ៊ុនរង់ចាំចំណាត់ការរបស់ស្ថាប័នមានសមត្ថកិច្ច។

**ករណីទី២៖** ក្រុមហ៊ុនបានសហការជាមួយមេភូមិពស់វែក មេឃុំរស្មីសាមគ្គី និងប្រជាជនដែលទាមទារក្បាលដីទាំងនោះ ដើម្បីពិនិត្យស្ថានភាពជាក់ស្តែង នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧។ ជាលទ្ធផល ក្រុមការងារបានចុះដល់ទីតាំងទំនាស់ និងពិនិត្យឃើញថា ដីដែលប្រជាជនទាមទារផ្នែកខ្លះជាដីអាស្រ័យដោយដាំដុះដំណាំដូចជាត្រាវ ស្វាយខ្នុរ ហើយមួយផ្នែកទៀតជាដីចំណីអូរដែលបានកាត់ចេញសម្រាប់ការពារប្រភពទឹក ស្ថិតនៅក្នុងក្បាលដីផលិតកម្មរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីរួច។ តំណាងក្រុមហ៊ុនបានជម្រាបជូនអាជ្ញាធរដែនដី និងប្រជាជនទាំងអស់ថាដោយតំបន់ទាមទារនេះមិនត្រូវបានកាត់ឆ្វៀលចេញក្នុងអំឡុងនិស្សិតចុះវាស់វែងនោះទេ (០១ បប) តែផ្ទុយទៅវិញវាស្ថិតនៅក្នុងតំបន់ការពារប្រភពទឹក និងក្នុងក្បាលដីរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីរួច។ ដូចនេះ ក្រុមហ៊ុនមិនហ៊ានសម្រេចអ្វីក្រៅពីការពារដីដែលបានជួលពីរដ្ឋាភិបាល (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) នោះទេ ប៉ុន្តែបើប្រជាជនមិនព្រមនឹងចំណាត់ការនេះ ក្រុមហ៊ុនយើងខ្ញុំក៏ពុំយល់ទាស់ដែរចំពោះកិច្ចសុំអន្តរាគមន៍បន្ថែមពីស្ថាប័នមានសមត្ថកិច្ច ដើម្បីពិនិត្យ និងវាយតម្លៃបន្ត ហើយក្រុមហ៊ុនរីករាយនិងសហការ សម្របសម្រួលជានិច្ច។

**១៣.ទំហំដីឆ្វៀលតាមបទបញ្ជា ០១៖**..............គ្មាន.............. (ស្នើផ្តល់ឯកសារ)

**១៤.លទ្ធផលអនុវត្តខ្លឹមសារ ស.ជ.ណ តាមរបាយការណ៍របស់គណៈកម្មការអន្តរក្រសួង**(១)។

| លេខលិខិត សជណ | ខ្លឹមសារសម្រេចរបស់ សជណ | លទ្ធផលអនុវត្តបានតាមខ្លឹមសារសជណ |
|---|---|---|
| លិខិតលេខ. ១០៨៤ សជណ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី | អនុញ្ញាតអោយក្រុមហ៊ុនហ្វ្រែនឌីសជីមបើរ៍ អិលធីឌី បន្តនីតិវិធីដោះស្រាយផលប៉ះពាលជាមួយប្រជាជន និងចុះកិច្ចសន្យាឡើងវិញដោយបន្ថយរយៈពេលពី៧០ មកត្រឹម ៥០ឆ្នាំវិញ | • បានចុះបញ្ជីដីរួចរាល់<br>• ធ្វើអនុបយោគរួចរាល់ពីដីសាធារណៈ មកជាដីឯកជនរបស់រដ្ឋ<br>• បានបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច សម្រាប់ឆ្នាំ ២០១៤-២០១៥ និង ២០១៥ -២០១៦<br>• បានទទួលសេចក្តីព្រាងកិច្ចសន្យាកែតម្រូវពីក្រសួង ហើយក្រុមហ៊ុនកំពុងបកប្រែ និងធ្វើការពិនិត្យ |

| | | |
|---|---|---|
| | | • មេធាវីរបស់ក្រុមហ៊ុនបានពិភាក្សាមួយជំហានរួចរាល់ហើយជាមួយក្រសួង |

[១] គណកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

**១៥.ការអនុវត្តបន្ទាប់ពីការណែនាំរបស់ក្រសួង ឬខេត្ត ៖** (ស្នើផ្តល់ឯកសារ)

| ល.រ | លេខលិខិត ខ្លឹមសារ | លទ្ធផលអនុវត្តតាមការណែនាំ |
|---|---|---|
| ១ | លិខិតលេខ ៧៦៤០ កសក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋ | ក្រុមហ៊ុនបានឆ្លើយតបទៅគណៈកម្មការអន្តរក្រសួងចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ តាមលិខិតលេខ ០០៦/១៧ ហ្គ្រ.ធ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីករណីបង់ថ្លៃសម្បទានសេដ្ឋកិច្ចចូលថវិការដ្ឋរួចរាល់ហើយ និងរង់ចាំនីតិវិធីបន្តពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរៀបចំការទូរទាត់ |

**១៦.សំណូមពររបស់ក្រុមហ៊ុន ៖**

តាមរយៈការបញ្ជាក់ខាងលើ ក្រុមហ៊ុនហ្គ្រែនឌីស ធីមប៊ើរ អិលធីឌី ក៏នៅមានសកម្មភាពមួយចំនួនដែលកំពុងជាប់គាំង និងមិនអាចបន្តដំណើរការអភិវឌ្ឍន៍ទៀតបាន ដោយសារសំណើសុំឈូសឆាយដែលបានដាក់ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនទាន់មានការឆ្លើយតបនៅឡើយ។ លើសពីនេះទៀត សំណើសាកល្បងដាំដុះដំណាំអំពៅក៏ពុំទាន់ទទួលបានលិខិតអនុញ្ញាតនោះដែរ។ គួរបញ្ជាក់ផងដែរថា ពេលវេលានៃការអនុវត្ត និងរៀបចំផែនការប្រត្តិបត្តិក៏កាន់តែខ្លីទៅៗសម្រាប់យើងខ្ញុំ ដូចនេះ ក្រុមហ៊ុនស្នើសុំមន្ទីរ និងស្ថាប័នពាក់ព័ន្ធមេត្តាគាំទ្រ និងជួយពន្លឿននីតិវិធីដូចខាងក្រោម៖

- សូមជួយពន្លឿនដំណើរការផ្តល់លិខិតអនុញ្ញាតឈូសឆាយដី ១ ២១២ ហិកតា ដើម្បីក្រុមហ៊ុនមានលទ្ធផលរៀបចំផែនការសម្រាប់អភិវឌ្ឍន៍នាឆ្នាំបន្ទាប់បានកាន់តែប្រសើរ
- សូមគាំទ្រ និងផ្តល់លិខិតអនុញ្ញាតស្នើសុំសាកល្បងដាំដុះដំណាំអំពៅ ក្នុងគោលបំណងពិនិត្យលើសក្តានុពលសេដ្ឋកិច្ច ការគ្រប់គ្រងរុក្ខជាតិចង្រៃ និងបង្កើនជីជាតិដី បន្ទាប់ពីចប់វដ្តនៃការប្រមូលផលអំពៅ និងឈានដល់ការដាំដុះដំណាំចំបង (ម៉ៃសាក់) និងប្រភេទឈើផ្សេងៗទៀត
- ស្នើសុំគាំទ្រ និងផ្តល់មន្ត្រីបច្ចេកទេស ដើម្បីជួយទប់ស្កាត់ការរំលោភយកដីធ្វើជាកម្មសិទ្ធិពីសំណាក់ជនខិលខូច

ធ្វើនៅភ្នំពេញ, ថ្ងៃទី ០៦ ខែ... ឆ្នាំ២០១៧

**នាយកប្រត្តិបត្តិ**

ហ្គ្រែនឌីស ធីមប៊ើរ អិលធីឌី
GRANDIS TIMBER LTD.

យូ យិន ក្រាមវិនខេល